# ផ្សិតព្រៃដ៏គ្រោះថ្នាក់

> ផ្សិតព្រៃដ៏គ្រោះថ្នាក់ជាធម្មតាលេចឡើង បន្ទាប់ពីការធ្លាក់ភ្លៀងដ៏ល្អលើកដំបូងនៅរដូវស្លឹកឈើជ្រុះ។

> គេអាចរកឃើញវានៅកន្លែងជាច្រើន រួមទាំងដីមានព្រៃស៊ុបទ្រុប ព្រៃឈើ សួនសាធារណៈ សួនកុមារ ទីវាលសាលា វាលស្រែចំការ ហើយនៅក្បែរៗផ្ទះនៅក្នុងសួនផ្ទាល់ខ្លួនរបស់អ្នក ដីកំប៉ុស កំទេចឈើ ឬចំបើង។

> សូមឃ្លាំមើលកូនៗ និងសត្វចិញ្ចឹមរបស់អ្នក នៅពេលអ្នកនៅខាងក្រៅ ពីព្រោះវាងាយស្រួលនឹងទៅក្បែរផ្សិត ហើយមើលទៅគួរឱ្យចាប់អារម្មណ៍ដើម្បីបរិភោគ។

> អ្នកដែលធ្លាប់រស់នៅបរទេសគួរតែដឹងថា ផ្សិតពុលនៅក្នុងប្រទេសអូស្ត្រាលី អាចមើលទៅដូចផ្សិតដែលអាចបរិភោគបាន ដែលគេរកឃើញមានក្នុងប្រទេសផ្សេងទៀត។

> ផ្សិត Death cap mushrooms (ផ្សិតមានម្លូកដែលពុលដល់ស្លាប់) មានគ្រោះថ្នាក់បំផុត ហើយអាចបណ្តាលឱ្យខូចថ្លើមធ្ងន់ធ្ងរ។ ការចម្អិន ឬយកសំបកចេញ មិនយកជាតិពុលចេញទេ។ ផ្សិត Death cap ដុះជាមួយដើមឈើ oak, ដើមឈើ hazel និងដើម chestnut ប៉ុន្តែផ្សិតដ៏សាហាវអាចដុះនៅគ្រប់ទីកន្លែង។ ផ្សិតតែមួយគត់ដែលមានសុវត្ថិភាពក្នុងការបរិភោគ គឺជាផ្សិតដែលអ្នកទិញពីហាងលក់គ្រឿងទេស ឬផ្សារទំនើបដែលអាចទុកចិត្តបានប៉ុណ្ណោះ។

> ប្រសិនបើអ្នកណាម្នាក់បរិភោគផ្សិតព្រៃដោយចៃដន្យ កុំរង់ចាំឱ្យរោគសញ្ញាចាប់ផ្តើម **សូមទូរសព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីជាតិពុល តាមលេខ 13 11 26** ហើយធ្វើតាមការណែនាំរបស់ពួកគេ។
អ្នកណាដែលឈឺបន្ទាប់ពីបរិភោគផ្សិតព្រៃ គួរតែស្វែងរកការព្យាបាលជាបន្ទាន់។

**នៅពេលមានអាសន្ន សូមទូរសព្ទទៅលេខសូន្យបីដង (000)។**

## រោគសញ្ញានៃការពុលផ្សិតព្រៃរួមមាន៖

> ឈឺពោះរមួលយ៉ាងខ្លាំង
> ឈឺពោះ
> ក្អួត
> ចង្អោរ
> រាគ

រោគសញ្ញាជាធម្មតាចាប់ផ្តើមពី 3 ទៅ 6 ម៉ោង បន្ទាប់ពីបរិភោគផ្សិត ហើយអាចបន្តរហូតដល់ទៅ 3 ថ្ងៃ។
**ផ្សិតដែលមានគ្រោះថ្នាក់បំផុត អាចមានរោគសញ្ញាពន្យារដែលអាចចាប់ផ្តើមរហូតដល់ទៅ 24 ម៉ោងបន្ទាប់ពីបរិភោគ។**

**www.sahealth.sa.gov.au/mushroompoisoning**



Government of South Australia
SA Health

FIS: 22058